**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខៈ.......០០៧/១៨......វសកក.លក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆ្នាំ២០១៨ ។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ០៩ ផ្លូវលេខ២៨៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃ.ច័ន្ទ...៥...រោច... ខែ បឋមាសាឍ ឆ្នាំ......សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី .....០២........ខែ កក្កដា.... ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទង លេខៈ ០១១ ៩៥៦ ៥៦៨)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង១៤:៣០នាទី ថ្ងៃអង្គារ...៤...រោច ខែទុតិយាសាឍ ឆ្នាំ......សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ...៣១........ខែ កក្កដា... ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង១៤:៣០នាទី ថ្ងៃ.អង្គារ..៤..រោច.. ខែ ទុតិយាសាឍ ឆ្នាំ......សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី .....៣១......ខែ កក្កដា.... ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃពុធ...១៤..កើត. ខែ បឋមាសាឍ... ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី...២៧.......ខែ..មិថុនា....ឆ្នាំ ២០១៨
**នាយកវិទ្យាស្ថាន**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

ម៉ៅ សុភាព

**ចម្លងជូន**
- អគ្គនាយកដ្ឋានលទ្ធកម្ម (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- ឯកសារ កាលប្បវត្តិ